ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា

លេខ ០០៧ ស.អ.យ.

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

រាជធានីភ្នំពេញ ថ្ងៃទី១២ ខែ ធ្នូ ឆ្នាំ ២០១២

# សារាចរណែនាំ

## ស្តីពី

## ការដំឡើងតម្លៃឯកតានៃសន្ទស្សន៍បៀវត្សមូលដ្ឋានសម្រាប់និវត្តជន និងជនបាត់បង់សម្បទាវិជ្ជាជីវៈ ដែលជាអតីតមន្ត្រីរាជការស៊ីវិល

ដើម្បីអនុវត្តគោលនយោបាយជាតិស្តីពីការលើកកម្ពស់សុខុមាលភាពសង្គមលើវិស័យសោធន សម្រាប់និវត្តជន និងជនបាត់បង់សម្បទាវិជ្ជាជីវៈ ដែលជាអតីតមន្ត្រីរាជការស៊ីវិល ស្របតាមកម្មវិធីនយោបាយយុទ្ធសាស្ត្រចតុកោណរបស់រាជរដ្ឋាភិបាល ក្រោមការដឹកនាំប្រកបដោយគតិបណ្ឌិតរបស់សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា សូមធ្វើការណែនាំគ្រប់ប្រធានមន្ទីរសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទារាជធានី ខេត្ត ត្រូវអនុវត្តស្របតាមស្មារតីអនុក្រឹត្យលេខ ២១៤ អនក្រ.បក ចុះថ្ងៃទី ២៦ ខែ វិច្ឆិកា ឆ្នាំ ២០១២ ស្តីពីការកែប្រែតម្លៃឯកតា នៃសន្ទស្សន៍បៀវត្សមូលដ្ឋាន និងការបង្កើនបៀវត្សសុទ្ធសាធរបស់មន្ត្រីរាជការ ដោយត្រូវគណនាតាមរូបមន្តដូចតទៅ ៖

១. ការដំឡើងតម្លៃឯកតា នៃសន្ទស្សន៍បៀវត្សមូលដ្ឋានចំនួន១.៥២០ រៀល ក្នុងមួយសន្ទស្សន៍ សម្រាប់ឆ្នាំ២០១៣ របស់និវត្តជន ត្រូវគណនាតាមរូបមន្តដូចខាងក្រោម ៖

| | | |
|---|---|---|
| ប្រាក់សោធនសរុបប្រចាំខែថ្មី | = | ប្រាក់សោធនសុទ្ធសាធ + ប្រាក់ដំឡើងឱ្យស្មើបៀវត្សមូលដ្ឋានអប្បបរមា + ប្រាក់បង្គ្រប់ + ប្រាក់បន្ថែមឱ្យស្មើប្រាក់សោធនចាស់ + ប្រាក់វិភាជន៍គ្រួសារ + ប្រាក់ហានិភ័យ + ប្រាក់ឧបត្ថម្ភផ្សេងទៀតប្រសិនបើមាន |
| ប្រាក់សោធនសុទ្ធសាធ | = | សន្ទស្សន៍បៀវត្សមូលដ្ឋាន × ១.៥២០ រៀល × អត្រាភាគរយប្រាក់សោធន |

២. ការដំឡើងតម្លៃឯកតា នៃសន្ទស្សន៍បៀវត្សមូលដ្ឋានចំនួន១.៥២០ រៀល ក្នុងមួយសន្ទស្សន៍ សម្រាប់ឆ្នាំ២០១៣ របស់ជនបាត់បង់សម្បទាវិជ្ជាជីវៈ ត្រូវគណនាតាមរូបមន្តដូចខាងក្រោម ៖

| | | |
|---|---|---|
| ប្រាក់សោធនសរុបប្រចាំខែថ្មី | = | ប្រាក់សោធនសុទ្ធសាធ + ប្រាក់ដំឡើងឱ្យស្មើ ៨០% នៃបៀវត្សមូលដ្ឋានអប្បបរមា + ប្រាក់បង្គ្រប់ + ប្រាក់បន្ថែមឱ្យស្មើប្រាក់សោធនចាស់ + ប្រាក់វិភាជន៍គ្រួសារ + ប្រាក់ហានិភ័យ + ប្រាក់ឧបត្ថម្ភផ្សេងទៀតប្រសិនបើមាន |
| ប្រាក់សោធនសុទ្ធសាធ | = | សន្ទស្សន៍បៀវត្សមូលដ្ឋាន × ១.៥២០ រៀល × អត្រាភាគរយប្រាក់សោធន |

៣. មន្ត្រីរាជការស៊ីវិលដែលត្រូវបានដាក់ឱ្យចូលនិវត្តន៍ ឬចូលបាត់បង់សម្បទាវិជ្ជាជីវៈ ដោយក្រសួង ស្ថាប័នសាមី ចាប់ពីថ្ងៃទី០១ ខែ មករា ឆ្នាំ ២០១៣ ត្រូវគណនាដំឡើងតម្លៃឯកតា នៃសន្ទស្សន៍បៀវត្សមូលដ្ឋានចំនួន ១.៥២០ រៀល ក្នុងមួយសន្ទស្សន៍ ត្រូវគិតតាមរូបមន្តដូចខាងលើនេះផងដែរ ។

៤. ត្រូវរៀបចំសំណុំលិខិត និងបែបបទស្របតាមនីតិវិធី ដើម្បីដំឡើងតម្លៃឯកតា នៃសន្ទស្សន៍បៀវត្សមូលដ្ឋានចំនួន ១.៥២០ រៀល ក្នុងមួយសន្ទស្សន៍របស់និវត្តជន និងជនបាត់បង់សម្បទាវិជ្ជាជីវៈ ដែលជាអតីតមន្ត្រីរាជការស៊ីវិល ដែលមានសំណុំលិខិត និងបែបបទដូចមានខាងក្រោម ៖

- សំណើសុំដំឡើងប្រាក់សោធនជូននិវត្តជន និងជនបាត់បង់សម្បទាវិជ្ជាជីវៈ ចំនួន ០២ ច្បាប់
- តារាងបើកប្រាក់សោធននិវត្តន៍ និងសោធនបាត់បង់សម្បទាវិជ្ជាជីវៈ ប្រចាំខែចុងក្រោយ ចំនួន ០២ ច្បាប់
- តារាងបើកប្រាក់សោធននិវត្តន៍ និងសោធនបាត់បង់សម្បទាវិជ្ជាជីវៈ ប្រចាំខែថ្មី ចំនួន ០៣ ច្បាប់



ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា អគារលេខ ៧៨៨ មហាវិថីព្រះមុនីវង្ស រាជធានីភ្នំពេញ ទូរស័ព្ទ/ទូរសារ ៖ [illegible] ២៣ ៧២[illegible]
Ministry of Social Affairs, Veterans and Youth Rehabilitation, #788, Monivong Blvd., Phnom Penh, Cambodia Fax/Phone: (855) 23 72[illegible] 86

- សំណុំលិខិត និងបែបបទទាំងអស់ត្រូវផ្ញើមកក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា ដោយបេឡាជាតិសន្តិសុខសង្គមសម្រាប់មន្ត្រីរាជការស៊ីវិល ត្រូវពិនិត្យផ្ទៀងផ្ទាត់ឱ្យបានហ្មត់ចត់ច្បាស់លាស់ ចំពោះប្រាក់គោលនយោបាយរបបសន្តិសុខសង្គមដែលបានអនុវត្តកន្លងមក ហើយត្រូវធ្វើរបាយការណ៍ជូនទៅក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា ។
- នៅពេលក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា បានឯកភាពដំឡើងតម្លៃឯកតា នៃសន្ទស្សន៍បៀវត្សមូលដ្ឋានលើតារាងប្រាក់សោធនប្រចាំខែ គ្រប់ប្រធានមន្ទីរសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទារាជធានី ខេត្ត ត្រូវចុះហត្ថលេខានៅលើទំព័រតារាងដែលបានចែងពីកាលបរិច្ឆេទដំឡើងតម្លៃឯកតា នៃសន្ទស្សន៍បៀវត្សមូលដ្ឋានលើប្រាក់សោធនប្រចាំខែ នៅក្នុងសៀវភៅនិវត្តជន និងសៀវភៅជនបាត់បង់សម្បទាវិជ្ជាជីវៈចាស់ លើទំព័រដែលបានចែងពីកាលបរិច្ឆេទដំឡើងតម្លៃឯកតា នៃសន្ទស្សន៍បៀវត្សមូលដ្ឋានលើប្រាក់សោធនប្រចាំខែ ។

៥ . គ្រប់ប្រធានមន្ទីរសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទារាជធានី ខេត្ត ត្រូវលើកសំណើដោយភ្ជាប់នូវសំណុំលិខិត និងបែបបទដំឡើងតម្លៃឯកតា នៃសន្ទស្សន៍បៀវត្សមូលដ្ឋាន ចំនួន ១.៥២០ រៀល ក្នុងមួយសន្ទស្សន៍របស់និវត្តជន និងជនបាត់បង់សម្បទាវិជ្ជាជីវៈ ទៅក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ឱ្យបានទាន់ពេលវេលា ដោយកំណត់ត្រឹមថ្ងៃទី ៣១ ខែ ធ្នូ ឆ្នាំ ២០១២ ជាកំហិត ។ ក្នុងករណីមានការយឺតយ៉ាវ និងមានភាពមិនប្រក្រតី ត្រូវទទួលខុសត្រូវចំពោះមុខច្បាប់ ។

៦ . គ្រប់ប្រធានមន្ទីរសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទារាជធានី ខេត្ត ត្រូវអនុវត្តការដំឡើងតម្លៃឯកតា នៃសន្ទស្សន៍បៀវត្សមូលដ្ឋាន ចំនួន ១.៥២០ រៀល ក្នុងមួយសន្ទស្សន៍ លើប្រាក់សោធនប្រចាំខែរបស់និវត្តជន និងជនបាត់បង់សម្បទាវិជ្ជាជីវៈ ដោយត្រូវអនុវត្តចាប់ពីថ្ងៃទី ០១ ខែ មករា ឆ្នាំ ២០១៣ តទៅ ។

គ្រប់ប្រធានមន្ទីរសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទារាជធានី ខេត្ត ត្រូវជំរុញការអនុវត្តន៍សារាចរណែនាំនេះ ឱ្យបានទាន់ពេលវេលា ដោយត្រូវរាយការណ៍ជូនអភិបាល នៃគណៈអភិបាលរាជធានី ខេត្ត និងសម្របសម្រួលជាមួយមន្ត្រីជំនាញពាក់ព័ន្ធគ្រប់ថ្នាក់នៃក្រសួង ស្ថាប័ន ដោយស្មារតីទទួលខុសត្រូវខ្ពស់ ឱ្យទទួលបានលទ្ធផលប្រកបដោយប្រសិទ្ធភាព ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

**រដ្ឋមន្ត្រីក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា**

**អ៊ិត សំហេង**

__ចម្លងជូន__ :
- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ទីស្តីការគណៈរដ្ឋមន្ត្រី
- ខុទ្ទកាល័យសម្តេចតេជោនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យឯកឧត្តម លោកជំទាវ ឧបនាយករដ្ឋមន្ត្រី
- គ្រប់ក្រសួង ស្ថាប័ន
- អាជ្ញាធរសវនកម្មជាតិ
- អង្គភាពប្រឆាំងអំពើពុករលួយ
- ក្រុមប្រឹក្សាភិបាល នៃ ប.ជ.ស.
- សាលារាជធានី គ្រប់សាលាខេត្ត
  " ដើម្បីជូនជ្រាប "
- បេឡាជាតិសន្តិសុខសង្គមសម្រាប់មន្ត្រីរាជការស៊ីវិល
  " ដើម្បីអនុវត្ត "
- ឯកសារ កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ
៣៥៣

ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា
លេខ ០០៧ ស.អ.យ

រាជធានីភ្នំពេញ ថ្ងៃទី ០៤ ខែ វិច្ឆិកា ឆ្នាំ ២០០៤

# សារាចរណែនាំ

ដើម្បីអនុវត្តឱ្យមានប្រសិទ្ធភាព នូវអនុក្រឹត្យរបស់រាជរដ្ឋាភិបាល លេខ ៥៥ អនក្រ.បក ចុះថ្ងៃទី ០៦ ខែ តុលា ឆ្នាំ ១៩៩៧ ស្ដីពីការអនុវត្តន៍របបសោធននិវត្តន៍ និង សោធនបាត់បង់សម្បទាវិជ្ជាជីវៈ ចំពោះមន្ត្រីរាជការស៊ីវិល ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និង យុវនីតិសម្បទា សូមធ្វើការណែនាំអនុវត្តដូចខាងក្រោម ៖

## I- របបសោធននិវត្តន៍

អ្នករាជការស៊ីវិលទាំងពីរភេទមានសិទ្ធិទទួលប្រាក់សោធននិវត្តន៍បាន លុះត្រាតែបានបំពេញតាមលក្ខខណ្ឌដូចមានចែងក្នុងមាត្រា ១.២.៣ នៃអនុក្រឹត្យលេខ ៥៥ អនក្រ.បក ចុះថ្ងៃទី ០៦ ខែ តុលា ឆ្នាំ ១៩៩៧ ស្ដីពីការអនុវត្តន៍របបសោធននិវត្តន៍ និង សោធនបាត់បង់សម្បទាវិជ្ជាជីវៈ ចំពោះមន្ត្រីរាជការស៊ីវិល ។

### ក- ប្រាក់សោធននិវត្តន៍អតីតភាព

អ្នករាជការស៊ីវិលទាំងពីរភេទ មានសិទ្ធិទទួលរបបសោធននិវត្តន៍អតីតភាពស្មើ ៨០ ភាគរយ នៃបៀវត្សសុទ្ធសាធរបស់សាមីខ្លួន លុះត្រាតែបានបំពេញតាមលក្ខខណ្ឌពីរយ៉ាងដូចខាងក្រោម ៖

១- មានអាយុ ៥៥ ឆ្នាំយ៉ាងតិច និងមានអតីតភាពការងារ ៣០ ឆ្នាំយ៉ាងតិច

២- មានអតីតភាពការងារ ៣០ ឆ្នាំឡើងទៅ ហើយបានស្ម័គ្រចិត្តសុំចូលនិវត្តន៍ មុនអាយុ ៥៥ ឆ្នាំ។ ពាក្យស្នើសុំត្រូវធ្វើតាមរយៈអង្គភាពគ្រប់គ្រងផ្ទាល់ទៅប្រធានស្ថាប័ន របស់សាមីខ្លួន។

ប្រាក់សោធននិវត្តន៍អតីតភាពត្រូវអនុវត្តតាមរូបមន្តដូចខាងក្រោម ៖

| |
|---|
| សនិសុទ្ធសាធ = ៨០ % ប |

ប = ប្រាក់បៀវត្សសុទ្ធសាធ

សនិសុទ្ធសាធ = ប្រាក់សោធននិវត្តន៍សុទ្ធសាធ

ប្រាក់សោធននិវត្តន៍នេះត្រូវបានគិតបន្ថែម ប្រាក់តំបន់ នៅតាមតំបន់ដែលសាមីខ្លួនរស់នៅ ប្រាក់ប៉ះពាល់សុខភាព (ចំពោះអ្នករាជការដែលធ្វើការងារធ្ងន់ ការងារលំបាក ការងារប៉ះពាល់សុខភាព មុនពេលចូលនិវត្តន៍) ប្រាក់ឧបត្ថម្ភ ប្រពន្ធ កូន និង ប្រាក់ឧបត្ថម្ភផ្សេងៗទៀតដែលរដ្ឋបានកំណត់ ។

> សនិ = ៨០%ប+៣០%ប+ត+ប្រាក់ប៉ះពាល់សុខភាព+ប្រាក់ឧបត្ថម្ភប្រពន្ធ+ប្រាក់ឧបត្ថម្ភកូន+
> ប្រាក់ឧបត្ថម្ភផ្សេងៗទៀត ( បើមាន )

សនិ = ប្រាក់សោធននិវត្តន៍សរុបប្រចាំខែ

៣០%ប = ប្រាក់ឧបត្ថម្ភ៣០% លើប្រាក់បៀវត្សសុទ្ធសាធ

ត = ប្រាក់តំបន់ដែលសាមីជនរស់នៅ ( បើមាន )

**ខ. ប្រាក់សោធននិវត្តន៍អតិបរមា**

អ្នករាជការស៊ីវិលទាំងពីរភេទ មានសិទ្ធិទទួលប្រាក់សោធននិវត្តន៍អប្បបរមាស្មើ នឹង ៦០% នៃប្រាក់បៀវត្សសុទ្ធសាធរបស់សាមីខ្លួន លុះត្រាតែបានបំពេញលក្ខខណ្ឌដូចមានខាងក្រោម ៖

- មានអាយុ ៥៥ ឆ្នាំ យ៉ាងតិច
- មានអតីតភាពការងារ ពី ២០ ឆ្នាំ ឡើង

ក្នុងករណីមានអតីតភាពការងារលើសពី ២០ ឆ្នាំ អ្នករាជការនោះមានសិទ្ធិទទួលប្រាក់សមាមាត្របន្ថែម ២ % ក្នុងមួយឆ្នាំលើប្រាក់បៀវត្សសុទ្ធសាធរបស់សាមីខ្លួន ។ ប្រាក់សោធនសមាមាត្រនេះ មិនត្រូវខ្ពស់ជាងប្រាក់សោធននិវត្តន៍អតីតភាព ៨០ % នៃប្រាក់បៀវត្សសុទ្ធសាធឡើយ បើមានករណីខ្ពស់ជាងត្រូវបន្ថយអោយស្មើនឹង ៨០ % នៃប្រាក់បៀវត្សសុទ្ធសាធវិញ និង មិនត្រូវទាបជាងប្រាក់បៀវត្សអប្បបរមាសុទ្ធសាធប្រចាំខែនៃតារាងកាំប្រាក់របស់សាមីខ្លួនឡើយ ។ បើមានករណីទាបជាងប្រាក់បៀវត្សអប្បបរមាសុទ្ធសាធ ត្រូវដំឡើងអោយស្មើនឹងប្រាក់បៀវត្សអប្បបរមាសុទ្ធសាធនៃតារាងកាំប្រាក់របស់សាមីខ្លួន ។

> សនិ = [ ៦០%+២%(ឆ-២០)]ប +៣០%ប +ត+ប្រាក់ប៉ះពាល់សុខភាព + ប្រាក់ឧបត្ថម្ភប្រពន្ធ+
> ប្រាក់ឧបត្ថម្ភកូន+ ប្រាក់ឧបត្ថម្ភផ្សេងៗទៀត (បើមាន)

សនិ = ប្រាក់សោធននិវត្តន៍សរុបប្រចាំខែ

ប = ប្រាក់បៀវត្សសុទ្ធសាធ

ឆ = ចំនួនឆ្នាំលើសពី ២០ ឆ្នាំ ដល់ក្រោម ៣០ ឆ្នាំ ( ២០< ឆ<៣០)

[ ៦០%+២%(ឆ-២០)]ប = ប្រាក់សោធននិវត្តន៍សុទ្ធសាធ

ប្រាក់បៀវត្សអប្បបរមា ≤ [ ៦០%+២%(ឆ-២០)]ប ≤ ៨០%ប

៣០ %ប= ប្រាក់ឧបត្ថម្ភបន្ថែម ៣០ % លើបៀវត្សសុទ្ធសាធ

គ - អ្នករាជការដែលត្រូវបានក្រសួង ស្ថាប័ន ប្រកាសអោយចូលនិវត្តន៍ ត្រូវបានទទួលប្រាក់ឧបត្ថម្ភម្តងគត់ស្មើនឹង បៀវត្សសរុបប្រចាំខែចំនួន ៨ ខែ ។ ប្រាក់ឧបត្ថម្ភនេះអាស្រ័យដោយក្រសួងស្ថាប័នរបស់សាមីជនជាអ្នកទទួលបន្ទុកដោះស្រាយ ។

ឃ - អ្នករាជការដែលមានអាយុគ្រប់ចូលនិវត្តន៍ ប៉ុន្តែមានអតីតភាពការងារតិចជាង ២០ ឆ្នាំ មិនត្រូវផ្តល់ប្រាក់សោធននិវត្តន៍ឡើយ ។ ក្នុងករណីនេះរដ្ឋផ្តល់ប្រាក់ឧបត្ថម្ភម្តងគត់ ដូចមានចែងក្នុងមាត្រា ៦ នៃអនុក្រឹត្យលេខ ៥៩ អនក្រ.បក ចុះថ្ងៃទី ០៦ ខែ តុលា ឆ្នាំ ១៩៩៧ ។ ការដោះស្រាយប្រាក់ឧបត្ថម្ភមួយលើក អាស្រ័យដោយស្ថាប័នគ្រប់គ្រងរបស់សាមីខ្លួន ។

| |
|---|
| បស×៨ ≤ បឧ ≤ បស × ១០ |

បស = ប្រាក់បៀវត្សសរុបប្រចាំខែ

បឧ = ប្រាក់ឧបត្ថម្ភមួយលើក

ខ-ការកំណត់ប្រាក់តំបន់ ប្រាក់ប៉ះពាល់សុខភាព ប្រាក់ឧបត្ថម្ភប្រពន្ធ កូន ត្រូវអនុវត្តតាមអនុក្រឹត្យរបស់ក្រុមប្រឹក្សារដ្ឋមន្ត្រីលេខ ០៥ អនក្រ.បក ចុះថ្ងៃទី ១១ខែ មិនា ឆ្នាំ ១៩៩២ ស្តីពីការកែលំអប្រាក់បៀវត្សកម្មាភិបាល បុគ្គលិក កម្មកររដ្ឋ និងសារាចរណែនាំអនុវត្តអនុក្រឹត្យនេះ របស់ក្រសួងពីរដូចខាងក្រោម ៖

១- ក្រសួងផែនការលេខ ០១ សរណន ផក ចុះថ្ងៃទី ១៩ ខែ មិនា ឆ្នាំ ១៩៩២

២- ក្រសួងការងារ និង សង្គមកិច្ចលេខ ០៣ សរណនបស ចុះថ្ងៃទី ១៥ ខែឧសភា ឆ្នាំ ១៩៩២

ការបន្ថែមប្រាក់ ១០% លើបៀវត្សសុទ្ធសាធរបស់មន្ត្រីរាជការ ត្រូវអនុវត្តតាមលិខិតរបស់ក្រសួងផែនការលេខ ៣១២ ផក ចុះថ្ងៃទី ២០ ខែ សីហា ឆ្នាំ ១៩៩២ ។

ការបន្ថែមប្រាក់ ២០% លើបៀវត្សសុទ្ធសាធរបស់មន្ត្រីរាជការ ត្រូវអនុវត្តតាមលិខិតរបស់ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ លេខ ០៣២ កហវ ចុះថ្ងៃទី ០៤ ខែ វិច្ឆិកា ឆ្នាំ ១៩៩៣ ។

គ- របៀបគិតរយៈពេលបំពេញការងាររបស់អ្នករាជការ ត្រូវបានអនុវត្តតាមមាត្រា ៨ នៃអនុក្រឹត្យ

លេខ ៥៩ អនក្រ.បក ចុះថ្ងៃទី ០៦ ខែ តុលា ឆ្នាំ ១៩៩៧ ស្តីពីការអនុវត្តរបបសោធននិវត្តន៍ និងសោធនបាត់បង់សមត្ថភាពវិជ្ជាជីវៈ ចំពោះមន្ត្រីរាជការស៊ីវិល ។

រយៈពេលបំរើការងារក្រៅក្របខណ្ឌរដ្ឋ មិនត្រូវបានគិតជាឆ្នាំបំរើការងារឡើយ ។

ឥ- នៅពេលនិវត្តជនទទួលមរណភាព គ្រួសារនៃសពត្រូវបានផ្តល់ប្រាក់ឧបត្ថម្ភដូចមានចែងក្នុងមាត្រា ១០ នៃអនុក្រឹត្យលេខ ៥៩ អនក្រ.បក ចុះថ្ងៃទី ០៦ ខែ តុលា ឆ្នាំ ១៩៩៧ ។ ការផ្តាច់ប្រាក់សោធននិវត្តន៍ប្រចាំខែរបស់និវត្តជន ដែលបានទទួលមរណភាពខាងលើនេះ ត្រូវបានអនុវត្តនៅខែបន្ទាប់ ។ ឧទាហរណ៍និវត្តជនម្នាក់ស្លាប់នៅថ្ងៃទី ២២ ខែ តុលា ឆ្នាំ ១៩៩៧ ការផ្តាច់ប្រាក់សោធន ត្រូវបានអនុវត្តនៅថ្ងៃទី ០១ ខែ វិច្ឆិកា ឆ្នាំ ១៩៩៧ ។ក្នុងករណីគ្រួសារសពនិវត្តជន ពុំបានផ្តល់ពត៌មាន និង សំបុត្រមរណភាពអោយបានទាន់ក្នុងខែដែលបានស្លាប់ មន្ទីរសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា ខេត្ត ក្រុង ត្រូវអនុវត្តការបើកប្រាក់សោធនជូនគ្រួសារសពតាមធម្មតា ប៉ុន្តែក្រោយពេលបានទទួលពត៌មាន និង សំបុត្រមរណភាពត្រូវផ្តាច់ប្រាក់សោធននៅខែបន្ទាប់នៃការស្លាប់ ។ប្រាក់សោធនដែលបានបើករួចហើយត្រូវទូទាត់សងវិញ ។ កូនកំព្រាពីសពនិវត្តជន ត្រូវបានទទួលប្រាក់ឧបត្ថម្ភដូចកូនកំព្រានៃសពមន្ត្រីរាជការស៊ីវិលដែរ ។ ការផ្តល់ប្រាក់ឧបត្ថម្ភប្រចាំខែនេះ ត្រូវបានអនុវត្តចំពោះកូនកំព្រាដែលមានអាយុ រហូតដល់ ១៥ ឆ្នាំ និងចាប់ពីអាយុ១៥ ឆ្នាំឡើងទៅត្រូវមានលិខិតបញ្ជាក់ការសិក្សាពីនាយកសាលាដែលកូនកំព្រានោះបាននិងកំពុងសិក្សារៀនសូត្រ ។ លិខិតបញ្ជាក់ការសិក្សារបស់កូនកំព្រាទាំងនោះត្រូវផ្ញើមកក្រសួងសង្គមកិច្ច អតីតយុទ្ធជន និង យុវនីតិសម្បទា ជារៀងរាល់ចុងខែវិច្ឆិកា នៃឆ្នាំនីមួយៗក្នុងករណីដល់អាយុត្រូវបញ្ជាក់ការសិក្សា ហើយសាមីគ្រួសារកូនកំព្រាទាំងនោះ ពុំបានបំពេញ តាមការណែនាំរបស់ក្រសួង មន្ទីរសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា ខេត្ត ក្រុង ត្រូវធ្វើសំណើមកក្រសួងសង្គមកិច្ច អតីតយុទ្ធជន និង យុវនីតិសម្បទា ដើម្បីពិនិត្យផ្តាច់ប្រាក់ឧបត្ថម្ភប្រចាំខែនៃកូនកំព្រាទាំងនោះ ចាប់ពីថ្ងៃទី ០១ ខែ មករា នៃឆ្នាំបន្ទាប់ ។

ចំពោះសហព័ទ្ធនៃសពជាប្តី ឬប្រពន្ធ ដែលត្រូវបន្តទទួលប្រាក់ឧបត្ថម្ភប្រចាំខែបាន លុះត្រាតែប្តី ឬប្រពន្ធនោះពុំបានបំរើការងារក្នុងក្របខណ្ឌរដ្ឋ ។ប្រាក់ឧបត្ថម្ភប្រចាំខែរបស់ប្តីត្រូវអនុវត្តដូចប្រាក់ឧបត្ថម្ភប្រពន្ធដែរ ។ ការបើកប្រាក់ឧបត្ថម្ភនេះត្រូវបានអនុវត្តជារៀងរហូតដល់ពេលសហព័ទ្ធនៃសពត្រូវស្លាប់ ឬ មានគ្រួសារថ្មី ។នៅពេលសហព័ទ្ធនៃសពត្រូវបានទទួលមរណភាព ឬមានប្តី ប្រពន្ធថ្មីទៀត មន្ទីរសង្គមកិច្ច អតីតយុទ្ធជន និង យុវនីតិសម្បទា ខេត្ត ក្រុង ត្រូវធ្វើសំណើមកក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា ដើម្បីលុបឈ្មោះ និង ចុះទិដ្ឋាការលើសៀវភៅបើកប្រាក់ឧបត្ថម្ភ ។

## II- របបសោធនបាត់បង់សមត្ថភាពវិជ្ជាជីវៈ

អ្នករាជការស៊ីវិលទាំងពីរភេទ មានសិទ្ធិទទួលប្រាក់សោធនបាត់បង់សម្បទាវិជ្ជាជីវៈ បានលុះត្រាតែបានបំពេញលក្ខខណ្ឌដូចមានចែងក្នុងមាត្រា ១១ និង ១២ នៃអនុក្រឹត្យលេខ ៥៩ អនក្រ.បក ចុះថ្ងៃទី ០៦ ខែ តុលា ឆ្នាំ ១៩៩៧ ស្តីពីការអនុវត្តនីតិរបបសោធននិវត្តន៍ និង សោធនបាត់បង់សម្បទាវិជ្ជាជីវៈ ចំពោះមន្ត្រីរាជការស៊ីវិល ។

### គ- ប្រាក់សោធនបាត់បង់សម្បទាវិជ្ជាជីវៈ អតិបរមា :

អ្នករាជការទាំងពីរភេទ ដែលបាត់បង់សម្បទាវិជ្ជាជីវៈ ដោយគ្រោះថ្នាក់ការងារ ឬ បេសកកម្មត្រូវបានទទួលប្រាក់សោធនបាត់បង់សម្បទាវិជ្ជាជីវៈអតិបរមា ៦៥ % នៃប្រាក់បៀវត្សសុទ្ធសាធ ។

### ១- អំពីគ្រោះថ្នាក់ការងារ

ត្រូវបានចាត់ទុកជាគ្រោះថ្នាក់ការងារ គឺគ្រោះថ្នាក់ដែលកើតឡើងដោយធ្វើការ ឬ ក្នុងពេលធ្វើការក្នុងក្រសួង ស្ថាប័នទោះមានហេតុយ៉ាងណាក៏ដោយ ឬមានកំហុសមកពីអ្នករាជការ ឬគ្មានក៏ដោយ ហើយបណ្តាលអោយបាត់បង់សម្បទាវិជ្ជាជីវៈការងារ ទាំងស្រុង និង ជាអចិន្ត្រៃយ៍ ។

ឧទាហរណ៍ : គ្រោះថ្នាក់កើតឡើងក្នុងពេលម៉ោងធ្វើការទាំងក្នុង និង ក្រៅក្រសួង ស្ថាប័ន ដែលអ្នករាជការបានបំពេញភារកិច្ចរបស់ខ្លួន ។

- គ្រោះថ្នាក់ក្នុងរយៈពេលធ្វើការ និង នៅពេលមុន ឬ ក្រោយពេលធ្វើការ ដែលអ្នករាជការរៀបចំសំភារៈពលកម្ម ឬ ម៉ាស៊ីន ។

- គ្រោះថ្នាក់ក្នុងការបំពេញសេចក្តីត្រូវការផ្ទាល់របស់ខ្លួន ក្នុងរយៈពេលធ្វើការ ដូចជាពេលសំរាកហូបចុក និងពេលបំបាត់ក្លនកណ្តាលវេន ពេលសំអាតខ្លួននៅពេលក្រោយធ្វើការ ។

- គ្រោះថ្នាក់ដែលបណ្តាលមកពីកត្តាដែលមានគ្រោះថ្នាក់ខាងពុល ដោយមិនដឹងខ្លួនជាមុនក្នុងក្រសួង ស្ថាប័ន និង ក្នុង ផលិតកម្ម ហើយបណ្តាលអោយមានរបួសពុលសន្លប់ដល់អ្នករាជការ ហើយធ្វើអោយបាត់បង់សម្បទាវិជ្ជាជីវៈ ជាស្ថាពរនូវសមត្ថភាពការងារ ។

- គ្រោះថ្នាក់ដែលធ្លាក់លើអ្នករាជការ ក្នុងពេលអ្នកទាំងនោះធ្វើដំណើរពីលំនៅដ្ឋានខ្លួនឆ្ពោះទៅកន្លែងធ្វើការ ឬ វិលមកវិញដោយគ្មានឈប់ ឬ ដោយគ្មានវៀងទៅទីណាជាប្រយោជន៍ផ្ទាល់ខ្លួន ។

### ២- អំពីគ្រោះថ្នាក់ការងារក្នុងពេលបេសកកម្ម

- គ្រោះថ្នាក់នៅពេលអ្នករាជការបញ្ចេញនូវវីរភាព ក្នុងការបំពេញបេសកកម្ម ដែលក្រសួងស្ថាប័នអង្គភាព ប្រគល់អោយ ហើយបានលះបង់ជីវិតរបស់ខ្លួន ។

- គ្រោះថ្នាក់ដែលកើតឡើងក្នុងពេលអ្នករាជការការពារទ្រព្យសម្បត្តិរដ្ឋ ឬ សាធារណៈ ដូចជាភ្លើងឆេះផ្ទះ ទឹកជំនន់ ។ល។

- ប្រាក់សោធនបាត់បង់សម្បទាវិជ្ជាជីវៈអតិបរមា ត្រូវអនុវត្តតាមរូបមន្តដូចខាងក្រោម÷

**សពិសុទ្ធសាធ = ៦៥%ប**

សពិសុទ្ធសាធ = ប្រាក់សោធនបាត់បង់សម្បទាវិជ្ជាជីវៈសុទ្ធសាធ

ប្រាក់សោធនបាត់បង់សម្បទាវិជ្ជាជីវៈនេះត្រូវបានគិតបន្ថែមប្រាក់បំណាច់ទៅតាមតំបន់ដែលសាមីខ្លួនរស់នៅ ប្រាក់ប៉ះពាល់សុខភាព(ចំពោះអ្នកជការដែលធ្វើការងារធ្ងន់ ការងារលំបាក ការងារប៉ះពាល់សុខភាព ដូចពេលកំពុងបំរើការងារមុនពេលចូលបាត់បង់សម្បទាវិជ្ជាជីវៈ) ប្រាក់ឧបត្ថម្ភប្រពន្ធ កូន និង ប្រាក់ឧបត្ថម្ភផ្សេងៗទៀតដែលរដ្ឋបានកំណត់ ៖

សពិ = ៦៥%ប – ៣០%ប + ត + ប្រាក់ប៉ះពាល់សុខភាព + ប្រាក់ឧបត្ថម្ភប្រពន្ធ + ប្រាក់ឧបត្ថម្ភកូន + ប្រាក់ឧបត្ថម្ភផ្សេងៗទៀត (បើមាន)

សពិ = ប្រាក់សោធនបាត់បង់សម្បទាវិជ្ជាជីវៈប្រចាំខែ

៣០%ប = ប្រាក់ឧបត្ថម្ភ៣០%លើប្រាក់បៀវត្សសុទ្ធសាធ

### ខ- ប្រាក់សោធនបាត់បង់សម្បទាវិជ្ជាជីវៈអប្បបរមា

ប្រាក់សោធនបាត់បង់សម្បទាវិជ្ជាជីវៈអប្បបរមា ត្រូវកំណត់ ៥០ % នៃប្រាក់បៀវត្សសុទ្ធសាធ។ ប្រាក់សោធននេះត្រូវអនុវត្តតែចំពោះអ្នកជការណាដែលបាត់បង់សម្បទាវិជ្ជាជីវៈ ដោយសារជំងឺ ឬ គ្រោះថ្នាក់ផ្សេងៗ។ ចំពោះអ្នកជការដែលមានអតីតភាពការងារលើសពី ២០ ឆ្នាំឡើងទៅ ត្រូវទទួលប្រាក់សោធនបាត់បង់-សម្បទាវិជ្ជាជីវៈអប្បបរមា និងត្រូវបានទទួលប្រាក់សមាមាត្របន្ថែម ១,៥ % ក្នុងមួយឆ្នាំលើប្រាក់បៀវត្សសុទ្ធសាធរបស់សាមីខ្លួន ។ ប៉ុន្តែប្រាក់សោធនសមាមាត្រនេះ មិនត្រូវលើសប្រាក់សោធនបាត់បង់សម្បទាវិជ្ជាជីវៈអតិបរមា ឬ មិនត្រូវទាបជាង ៥០ % នៃប្រាក់បៀវត្សអប្បបរមាសុទ្ធសាធ នៃតារាងតំប្រាក់របស់សាមីខ្លួនឡើយ។

សពិសុទ្ធសាធ = [ ៥០% + ១,៥% (ឆ — ២០) ]ប

ឆ = ចំនួនឆ្នាំដែលបានបំរើការងាររដ្ឋលើសពី ២០ឆ្នាំឡើង

២០ឆ្នាំ < ឆ < ៣០ ឆ្នាំ

៥០%ប ≤ [ ៥០% + ១,៥% (ឆ — ២០) ]ប ≤ ៦៥%ប

សពិ = [ ៥០% + ១,៥% ( ឆ − ២០ ) ] ប + ៣០% ប + គ + ប្រាក់ប៉ះពាល់សុខភាព + ប្រាក់ឧបត្ថម្ភប្រពន្ធ + ប្រាក់ឧបត្ថម្ភកូន + ប្រាក់ឧបត្ថម្ភផ្សេងៗទៀត (បើមាន)

៣. ការគណនាប្រាក់តំបន់ ប្រាក់ប៉ះពាល់សុខភាព ប្រាក់ឧបត្ថម្ភប្រពន្ធ កូន ត្រូវបានអនុវត្តដូចនិវត្តជនដែរ។

៤. អ្នករាជការដែលបាត់បង់សម្បទាវិជ្ជាជីវៈ ត្រូវបានអនុវត្តរបៀបគិតរយៈពេលបំពេញការងារ ដូចជានិវត្តជនដែរ ។ ដោយឡែកក្រោយពេលតំរូវអោយចូលបាត់បង់សម្បទាវិជ្ជាជីវៈ ត្រូវទទួលប្រាក់ឧបត្ថម្ភមួយគត់ស្មើនឹងប្រាក់បៀវត្សសរុប ប្រចាំខែចំនួន ៧ ខែ ។ ប្រាក់ឧបត្ថម្ភនេះ អាស្រ័យដោយក្រសួង ស្ថាប័ន របស់សាមីជនជាអ្នកទទួលបន្ទុកដោះស្រាយ ។

៥. អ្នករាជការដែលបាត់បង់សម្បទាវិជ្ជាជីវៈ នៅពេលទទួលមរណភាព គ្រួសារនៃសពត្រូវបានទទួលប្រាក់ឧបត្ថម្ភ ដូចមានចែងក្នុងមាត្រា ១៥ នៃអនុក្រឹត្យលេខ ៥៩ អនក្រ បកចុះថ្ងៃទី ០៦ ខែតុលា ឆ្នាំ១៩៩៧ ។

ចំពោះរបៀបរបបអនុវត្តការផ្តាច់ប្រាក់សោធន និង ការផ្តល់ប្រាក់ឧបត្ថម្ភគ្រួសារក្នុងបន្ទុកត្រូវអនុវត្តដូចនិវត្តជនទទួលមរណភាពដែរ ។

## III- ការទូទាត់ប្រាក់ឧបត្ថម្ភប្រពន្ធ កូនសំរាប់និវត្តជន និង ជនបាត់បង់សម្បទាវិជ្ជាជីវៈដែលទទួលប្រាក់សោធនប្រចាំខែកន្លងមក :

ការគិតបញ្ចូលប្រាក់ឧបត្ថម្ភ ប្រពន្ធ កូន ជូននិវត្តជន និង ជនបាត់បង់សម្បទាវិជ្ជាជីវៈ ដូចមានចែងក្នុងមាត្រា ១៧ នៃអនុក្រឹត្យ លេខ ៥៩ អនក្រ បក ចុះថ្ងៃទី ០៦ ខែ តុលា ឆ្នាំ ១៩៩៧ ត្រូវបានអនុវត្តចាប់ពីថ្ងៃទី ០១ ខែ មីនា ឆ្នាំ ១៩៩៨ តទៅ ។

និវត្តជន និង ជនបាត់បង់សម្បទាវិជ្ជាជីវៈ ដែលបានទទួលប្រាក់សោធនកន្លងមក ត្រូវគិតបញ្ចូលប្រាក់ឧបត្ថម្ភប្រពន្ធ ដែលពុំបានបំរើការងារក្នុងក្របខ័ណ្ឌរដ្ឋ និង ប្រាក់ឧបត្ថម្ភកូនក្នុងបន្ទុកដែលមានអាយុក្រោម១៥ ឆ្នាំ និងចាប់ពី អាយុ ១៥ ឆ្នាំឡើងត្រូវមានលិខិតបញ្ជាក់ការសិក្សាពីនាយកសាលាដែលកូននោះកំពុងសិក្សារៀនសូត្រ ។ ប្រពន្ធ និង កូន ដែលត្រូវផ្តាច់ប្រាក់ឧបត្ថម្ភប្រចាំខែ លុះត្រាតែមានករណីដូចខាងក្រោម ÷

- ប្រពន្ធស្លាប់
- កូនលើសអាយុ ១៥ ឆ្នាំ គ្មានលិខិតបញ្ជាក់ការសិក្សា ឬ មានអាពាហ៍ពិពាហ៍ ។

IV- ភារកិច្ច និង សមត្ថកិច្ចនៃការគ្រប់គ្រងបើកប្រាក់សោធននិវត្តន៍ និង សោធនបាត់បង់សម្បទា

* ចំពោះមុខ:

ក. ភារកិច្ចរបស់ក្រសួង ស្ថាប័ននីមួយៗមានដូចខាងក្រោម ៖

- ត្រូវលើកគំរោងផែនការស្ថិតិ និង ថវិកាប្រចាំឆ្នាំ សំរាប់អ្នកកាងារក្រោមឱវាទដែលគ្រប់ល័ក្ខខ័ណ្ឌចូលនិវត្តន៍ និង ចូលបាត់បង់សម្បទាវិជ្ជាជីវៈ ជូនក្រសួងសង្គមកិច្ច អតីតយុទ្ធជន និង យុវនីតិសម្បទា និង ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ អោយបានមុនដំណាច់ខែសីហានៃឆ្នាំ ដើម្បីបំរុងថវិកាសំរាប់បើកផ្តល់ជូននិវត្តជន និង ជនបាត់បង់សម្បទាវិជ្ជាជីវៈ ។ ចំពោះក្រសួង ស្ថាប័ន ដែលគ្មានគំរោងផែនការស្ថិតិ និង ថវិកាធ្វើមកតាមការកំណត់នោះ ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និង យុវនីតិសម្បទា ពុំអាចចេញសៀវភៅនិវត្តជន និង ជនបាត់បង់សម្បទា-វិជ្ជាជីវៈ ជូនបានឡើយ ។

- លើកគំរោងផែនការថវិកា និង បើកប្រាក់ឧបត្ថម្ភលើកដំបូងជូនអ្នកកាងារ ដែលបានប្រកាសអោយចូលនិវត្តន៍ និង ចូលបាត់បង់សម្បទាវិជ្ជាជីវៈ ។ ប្រាក់ឧបត្ថម្ភលើកដំបូងនេះ ត្រូវស្នើទៅក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ។

- ត្រូវធ្វើសំណើសុំចេញសៀវភៅនិវត្តជន និងជនបាត់បង់សម្បទាវិជ្ជាជីវៈ ទៅក្រសួងសង្គមកិច្ច អតីត-យុទ្ធជន និងយុវនីតិសម្បទា អោយបានបីខែមុនពេលប្រកាសអោយអ្នកកាងារក្រោមឱវាទចូលនិវត្តន៍ ឬ ចូលបាត់-បង់សម្បទាវិជ្ជាជីវៈ ។ សំណើយឺតយ៉ាវ មិនទាន់តាមកំណត់នេះ ក្រសួងមិនទទួលខុសត្រូវឡើយ ។ បណ្តាសំណុំលិខិតដែលត្រូវបញ្ជូន មកក្រសួងសង្គមកិច្ច អតីតយុទ្ធជន និង យុវនីតិសម្បទា មានដូចតទៅ ៖

- ពាក្យស្នើសុំចេញសៀវភៅនិវត្តជន ឬ ជនបាត់បង់សម្បទាវិជ្ជាជីវៈ ........ ចំនួន ០១ ច្បាប់
- ប្រកាសអោយចូលនិវត្តន៍ ឬចូលបាត់បង់សម្បទាវិជ្ជាជីវៈ (ច្បាប់ដើម ០១) ចំនួន ០៥ ច្បាប់
- លិខិតបញ្ជាក់អំពីរយៈពេលបំពេញការងាររបស់អ្នកកាងារ ........ ចំនួន ០៥ ច្បាប់
- ជីវប្រវត្តិសង្ខេបរបស់សាមីជន ........ ចំនួន ០៥ ច្បាប់
- ពាក្យសុំចូលនិវត្តន៍របស់អ្នកកាងារដែលមានអតីតភាពការងារ ៣០ ឆ្នាំឡើង មិនទាន់គ្រប់អាយុ ហើយស្ម័គ្រចិត្តសុំចូលនិវត្តន៍ ........ ចំនួន ០១ ច្បាប់
- សេចក្តីសំរេចអោយបន្តការងារមួយឆ្នាំម្តងៗ បើអ្នកកាងារនោះមានអាយុលើសពី ៥៥ ឆ្នាំ ឡើង ចំនួន ០១ ច្បាប់
- លិខិតបញ្ជាក់ការងារប៉ះពាល់សុខភាព បើអ្នកកាងារនោះធ្វើការនៅកន្លែងប៉ះពាល់សុខភាព ចំនួន ០១ ច្បាប់

- វិញ្ញាបនបត្របញ្ជាក់បាត់បង់សម្បទាវិជ្ជាជីវៈ ចេញដោយគណៈកម្មការវាយតំលៃសុខភាព បើអ្នកជាកម្មករនោះបាត់បង់សម្បទាវិជ្ជាជីវៈ ចំនួន ០១ ច្បាប់
- កំណត់ហេតុស្តីពីគ្រោះថ្នាក់ការងារ ឬបេសកកម្ម បើអ្នកជាកម្មករនោះទទួលគ្រោះថ្នាក់ដោយបំពេញការងារ ឬ បេសកកម្ម ចំនួន ០១ ច្បាប់
- រូបថតទំហំ ៤ គុណ ៦ ចំនួន ០៣ សន្លឹក
- រូបថតទំហំ ៣ គុណ ៤ ចំនួន ០១ សន្លឹក

ទំរង់បែបបទសំខាន់ៗខាងលើ ដូចមានគំរូជូនភ្ជាប់មកជាមួយនូវភាគឧបសម្ព័ន្ធ ។

## ខ.ភារកិច្ចរបស់ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និង យុវនីតិសម្បទា

### ១.ថ្នាក់កណ្តាល :

- ពិនិត្យសំណើសុំចេញសៀវភៅនិវត្តជន និង ជនបាត់បង់សម្បទាវិជ្ជាជីវៈ នៃអ្នករាជការរបស់ក្រសួងស្ថាប័នរដ្ឋ ។

- ចេញសៀវភៅបើកប្រាក់សោធនប្រចាំខែ និង អត្តសញ្ញាណប័ណ្ណ ជូននិវត្តជន និង ជនបាត់បង់សម្បទាវិជ្ជាជីវៈ ។

- ពិនិត្យ និង ចេញប្រកាសលុបឈ្មោះនិវត្តជន ឬជនបាត់បង់សម្បទាវិជ្ជាជីវៈ នៅពេលមុខសញ្ញាទទួលមរណភាព និង ចេញសៀវភៅបើកប្រាក់ឧបត្ថម្ភជូនគ្រួសារសព តាមសំណើរបស់មន្ទីរសង្គមកិច្ច អតីតយុទ្ធជន និង យុវនីតិសម្បទា ខេត្ត ក្រុង ។

- ពិនិត្យ និង ចេញសៀវភៅសោធនទុតិយតារបស់និវត្តជន និង ជនបាត់បង់សម្បទាវិជ្ជាជីវៈ នៅពេលសៀវភៅបើកប្រាក់សោធនប្រចាំខែត្រូវបាត់បង់ ឬ ប្រើប្រាស់អស់ ។

- ពិនិត្យ និង ផ្ទេរការផ្លាស់ប្តូរទីលំនៅរបស់និវត្តជន ជនបាត់បង់សម្បទាវិជ្ជាជីវៈ តាមសំណើរបស់មន្ទីរសង្គមកិច្ច អតីតយុទ្ធជន និង យុវនីតិសម្បទា ខេត្ត ក្រុង ។

- គ្រប់គ្រង តាមដានត្រួតពិនិត្យ និង វាយតំលៃការអនុវត្តនីតិវិធីគោលនយោបាយសោធននិវត្តន៍ សោធនបាត់បង់សម្បទាវិជ្ជាជីវៈ នៅគ្រប់លំដាប់ថ្នាក់ក្រោមឱវាទរបស់ក្រសួង ។

### ២.ថ្នាក់មន្ទីរសង្គមកិច្ច អតីតយុទ្ធជន និង យុវនីតិសម្បទា ខេត្ត ក្រុង :

- គ្រប់គ្រង និង បើកប្រាក់សោធនប្រចាំខែជូននិវត្តជន និង ជនបាត់បង់សម្បទាវិជ្ជាជីវៈ ដែលរស់នៅតាមខេត្តក្រុងរបស់ខ្លួន ។

- ជារៀងរាល់ឆ្នាំ មន្ទីរសង្គមកិច្ច អតីតយុទ្ធជន និង យុវនីតិសម្បទា ខេត្ត ក្រុង ត្រូវធ្វើជំរឿននិវ-

ការស្ថិតិ និង ថវិកា និវត្តជន និង ជនបាត់បង់សម្បទាវិជ្ជាជីវៈ និង គ្រួសារក្នុងបន្ទុករបស់ពួកគេក្នុងសមត្ថកិច្ច របស់ខេត្ត ក្រុង នោះ ដើម្បីផ្ញើមកក្រសួងសង្គមកិច្ច អតីតយុទ្ធជន និង យុវនីតិសម្បទា អោយបានមុនដំណាច់ខែ សីហា នៃឆ្នាំ ។

- ផ្ញើសំណើទៅក្រសួងសង្គមកិច្ច អតីតយុទ្ធជន និង យុវនីតិសម្បទា ដើម្បី ៖

២-១-លុបឈ្មោះនិវត្តជន ឬ ជនបាត់បង់សម្បទាវិជ្ជាជីវៈ នៅពេលមុខសញ្ញា នោះបានទទួលមរណភាព ដោយភ្ជាប់មកជាមួយនូវសំណុំលិខិតដូចខាងក្រោម ៖

- ពាក្យសុំប្រាក់ឧបត្ថម្ភគ្រួសារ ចំនួន ០១ ច្បាប់
- សំបុត្របញ្ជាក់មរណភាពរបស់និវត្តជន ឬ ជនបាត់បង់សម្បទាវិជ្ជាជីវៈ ចំនួន ០១ ច្បាប់
- វិញ្ញាបនប័ត្រផ្តាច់ទឹកប្រាក់សោធននិវត្តន៍
- សៀវភៅនិវត្តជន ឬ ជនបាត់បង់សម្បទាវិជ្ជាជីវៈ
- តារាងរៀបរាប់ស្ថានភាពគ្រួសារសេព ចំនួន ០១ ច្បាប់

២-២- សុំផ្ទេរការស្នាក់នៅរបស់និវត្តជន ឬ ជនបាត់បង់សម្បទាវិជ្ជាជីវៈ នៅពេលសាមីជនមានសំណើមកមន្ទីរសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា ។ សំណុំលិខិតត្រូវភ្ជាប់មកក្រសួងសង្គមកិច្ច អតីតយុទ្ធជន និង យុវនីតិសម្បទា មាន ៖

- ពាក្យសុំផ្ទេរការស្នាក់នៅរបស់មន្ទីរសង្គមកិច្ច អតីតយុទ្ធជន និង យុវនីតិសម្បទា ខេត្ត ក្រុង ចំនួន ០១ ច្បាប់
- តារាងទូទាត់ប្រាក់សោធនប្រចាំខែចុងក្រោយរបស់សាមីជន ចំនួន ០១ ច្បាប់
- ពាក្យស្នើសុំផ្ទេររបស់និវត្តជន ឬ ជនបាត់បង់សម្បទាវិជ្ជាជីវៈ ចំនួន ០១ ច្បាប់
- សៀវភៅនិវត្តជន ឬ ជនបាត់បង់សម្បទាវិជ្ជាជីវៈ

២-៣-សុំចេញសៀវភៅសោធនទុតិយតា ចំពោះករណី និវត្តជន ឬជនបាត់បង់សម្បទាវិជ្ជាជីវៈ ដែលបាត់បង់សៀវភៅសោធនចាស់ ។ សំណុំលិខិតភ្ជាប់មកជាមួយមាន ៖

- ពាក្យសុំចេញសៀវភៅទុតិយតារបស់មន្ទីរសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា ខេត្ត ក្រុង ចំនួន ០១ ច្បាប់
- កំណត់ហេតុស្តីពីការបាត់បង់សៀវភៅ ចំនួន ០១ ច្បាប់
- តារាងប្រាក់សោធនប្រចាំខែ ចំនួន ០១ ច្បាប់

២-៤-សុំចេញសៀវភៅថ្មីជូននិវត្តជន ឬជនបាត់បង់សម្បទាវិជ្ជាជីវៈ ក្នុងករណីសៀវភៅ

ចាស់ត្រូវបានប្រើប្រាស់អស់ ។ សំណុំលិខិតថ្មីទៅក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា រួមមាន ៖

- ពាក្យសុំចេញសៀវភៅថ្មី ដោយមន្ទីរសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា ខេត្ត ក្រុង ចំនួន ០១ ច្បាប់
- សៀវភៅនិវត្តជន ឬ ជនពិការបាត់បង់សម្បទាវិជ្ជាជីវៈ ដែលបានប្រើប្រាស់អស់ ។

២-៥-សុំបញ្ចូលប្រាក់ឧបត្ថម្ភប្រពន្ធ កូន របស់និវត្តជន ឬ ជនបាត់បង់សម្បទាវិជ្ជាជីវៈដែលកន្លងមកពុំបានទទួលប្រាក់ឧបត្ថម្ភ ។ សំណុំលិខិតភ្ជាប់មកជាមួយនេះរួមមាន ៖

- លិខិតស្នើសុំប្រាក់ឧបត្ថម្ភរបស់មន្ទីរសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា ខេត្ត ក្រុង ចំនួន ០១ ច្បាប់
- សៀវភៅនិវត្តជន ឬ ជនបាត់បង់សម្បទាវិជ្ជាជីវៈ
- តារាងរៀបរាប់ស្ថានភាពគ្រួសារ ដែលត្រូវបានទទួលប្រាក់ឧបត្ថម្ភប្រចាំខែ ចំនួន ០១ ច្បាប់ ( តារាងនេះត្រូវមានការបញ្ជាក់ពីអាជ្ញាធរមូលដ្ឋានភូមិ ឃុំ សង្កាត់ ស្រុក ខណ្ឌ ) ។

២-៦-សុំចេញអត្តសញ្ញាណបណ្ណជូននិវត្តជន ឬ ជនបាត់បង់សម្បទាវិជ្ជាជីវៈ ដែលកំពុងរស់នៅតាមខេត្តក្រុង របស់ខ្លួន ដោយភ្ជាប់មកជាមួយនូវបញ្ជីរាយនាម និង រូបថតទំហំ ៣ គុណ ៤ ចំនួន ០១ សន្លឹក

- ជារៀងរាល់ត្រីមាសនៃឆ្នាំ មន្ទីរសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា ខេត្ត ក្រុង ត្រូវផ្ញើបញ្ជីបើកប្រាក់សោធននិវត្តន៍ និង សោធនបាត់បង់សម្បទាវិជ្ជាជីវៈ និង តារាងបើកប្រាក់ឧបត្ថម្ភគ្រួសាររបស់និវត្តជន និងជនបាត់បង់សម្បទាវិជ្ជាជីវៈ ទៅក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា

- រាល់ការបើកប្រាក់សោធន និង ប្រាក់ឧបត្ថម្ភគ្រួសារប្រចាំខែរបស់និវត្តជន និង ជនបាត់បង់សម្បទាវិជ្ជាជីវៈ ត្រូវមានវត្តមានរបស់មន្ត្រីតំណាងការិយាល័យសង្គមកិច្ច ថ្នាក់ខេត្ត ក្រុង ថ្នាក់ស្រុក ខណ្ឌ ដើម្បីងាយស្រួលក្នុងការគ្រប់គ្រង

- អនុវត្តកម្មវិធីតាមដាន ត្រួតពិនិត្យ និង វាយតម្លៃ ស្ថានភាពជីវភាពរបស់និវត្តជន និង ជនបាត់បង់សម្បទាវិជ្ជាជីវៈ ព្រមទាំងគ្រួសារក្នុងបន្ទុក អោយបានជាប់ជាប្រចាំក្នុងមួយឆ្នាំយ៉ាងតិច ២ ដង ។ លទ្ធផលការងារនេះ ត្រូវមានរបាយការណ៍បញ្ជូនទៅក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា

- កំណត់ពេលនាំការកិច្ច ដាក់ស្នើសំរេចការិយាល័យក្រោមឱវាទរបស់មន្ទីរផ្ទាល់ ។

ទំរង់បែបបទសំខាន់ៗខាងលើ ដូចមានភ្ជាប់មកជាមួយនូវគោលនុបសម្ព័ន្ធ ។

V- អវសានប្បញ្ញត្តិ

ប្រកាសណែនាំអនុវត្តលេខ ៥៧ ប្រក.ការង. សអស ចុះថ្ងៃទី ១
សង្គមកិច្ច ការងារ និង អតីតយុទ្ធជន ត្រូវចាត់ទុកជានិរាករណ៍ ។

សេចក្តីណែនាំនេះមានប្រសិទ្ធភាពអនុវត្តចាប់ពីថ្ងៃចុះហត្ថលេខា

រដ្ឋមន្ត្រីក្រសួងសង្គមកិច្ច



ចម្លងជូន:

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ទីស្តីការគណៈរដ្ឋមន្ត្រី

  (ដើម្បីជូនជ្រាប)

- គ្រប់ក្រសួង ស្ថាប័ន នៃរាជរដ្ឋាភិបាល
- គ្រប់អង្គភាពក្រោមឱវាទ ក្រសួង ស.អ.យ
- គ្រប់មន្ទីរសង្គមកិច្ច អតីតយុទ្ធជន និង យុវនីតិសម្បទា ខេត្ត ក្រុង

  (ដើម្បីអនុវត្ត)

- ឯកសារ-កាលប្បវត្តិ